ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៥៧១ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុន គឿកហ្វាទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះដាក់ស្លែង និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ ក្បាលដី និងដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ ក្បាលដី នៅស្រុកសន្ទុក ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១០ សុណសធ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ដីសរុបទំហំ ៥៧១ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុន គៀកហ្វា ទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩៩ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលរួមមាន៖

-ផ្ទៃដីកាត់ចេញពីគម្របព្រៃឈើ ២០០២ ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១៣៨ គ្រួសារ

-ផ្ទៃដីកាត់ចេញពីក្រុមហ៊ុន គៀកហ្វា ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៦១ គ្រួសារ

**មាត្រា ៣ ..**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារ លើក្បាលដីចំនួន ៣៥០ ក្បាលដី និងដីកម្មសិទ្ធិសម្ភូហភាពរបស់វត្ត ០១ ក្បាលដី នៅភូមិអូរសោម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៦១៥...ចុះថ្ងៃទី..២៨.....ខែ..មិថុនា......ឆ្នាំ២០១២ ស្តីពីការកាត់ដីសរុបទំហំ ៥៧១ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើឆ្នាំ២០០២ ទំហំ ៤៣០ ហិកតា និងពីក្រុមហ៊ុនភឿកហ្វាទំហំ ១៤១ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ ដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងស្នើសុំផ្តល់សិទ្ធិជាកម្មសិទ្ធិសរុប ៣៥១ ក្បាលដី ក្នុងនោះជូនប្រជាពលរដ្ឋចំនួន ១៨៩ គ្រួសារលើក្បាលដីចំនួន ៣៥០ក្បាលដី និងដីកម្មសិទ្ធិសមូហភាពរបស់វត្ត ០១ក្បាលដី នៅស្រុកសន្ទុក ខេត្តកំពង់ធំ




| P-ID | Northing(m | Easthing(m | P-ID | Northing(m | Easthing(m | P-ID | Northing(m | Easthing(m | P-ID | Northing(m | Easthing(m |
|---|---|---|---|---|---|---|---|---|---|---|---|
| Projection UTM,Zone48N,Datum WGS84 | | | | | | Projection UTM,Zone48N,Datum WGS84 | | | | | |
| GPSMAP62s | | | | | | GPSMAP62s | | | | | |
| 1 | 558428 | 1386248 | 37 | 561187 | 1387667 | 73 | 560381 | 1386438 | 109 | 559864 | 1385595 |
| 2 | 558320 | 1386643 | 38 | 561154 | 1387666 | 74 | 560382 | 1386427 | 110 | 559868 | 1385612 |
| 3 | 558302 | 1386710 | 39 | 561156 | 1387656 | 75 | 560379 | 1386412 | 111 | 559877 | 1385649 |
| 4 | 558138 | 1386935 | 40 | 561171 | 1387592 | 76 | 560371 | 1386405 | 112 | 559878 | 1385654 |
| 5 | 558378 | 1387323 | 41 | 560928 | 1387552 | 77 | 560370 | 1386404 | 113 | 559879 | 1385658 |
| 6 | 558538 | 1387322 | 42 | 560903 | 1387529 | 78 | 560366 | 1386385 | 114 | 559811 | 1385700 |
| 7 | 559412 | 1387320 | 43 | 560885 | 1387446 | 79 | 560365 | 1386364 | 115 | 559675 | 1385783 |
| 8 | 559418 | 1387320 | 44 | 560856 | 1387454 | 80 | 560363 | 1386351 | 116 | 559674 | 1385783 |
| 9 | 559427 | 1387320 | 45 | 560879 | 1387444 | 81 | 560362 | 1386248 | 117 | 559621 | 1385826 |
| 10 | 559562 | 1387323 | 46 | 560911 | 1387408 | 82 | 560363 | 1386220 | 118 | 559625 | 1385848 |
| 11 | 559569 | 1387319 | 47 | 560896 | 1387383 | 83 | 560363 | 1386217 | 119 | 559570 | 1385879 |
| 12 | 559571 | 1387319 | 48 | 560875 | 1387298 | 84 | 560364 | 1386208 | 120 | 559504 | 1385907 |
| 13 | 559573 | 1387381 | 49 | 560865 | 1387276 | 85 | 560363 | 1386187 | 121 | 559482 | 1385917 |
| 14 | 559477 | 1388984 | 50 | 560855 | 1387267 | 86 | 560368 | 1386133 | 122 | 559461 | 1385926 |
| 15 | 559580 | 1388978 | 51 | 560809 | 1387223 | 87 | 560367 | 1386119 | 123 | 559436 | 1385937 |
| 16 | 559581 | 1388978 | 52 | 560760 | 1387188 | 88 | 560366 | 1386079 | 124 | 559423 | 1385943 |
| 17 | 559855 | 1388876 | 53 | 560766 | 1387179 | 89 | 560372 | 1386022 | 125 | 559404 | 1385951 |
| 18 | 560171 | 1388800 | 54 | 560774 | 1387158 | 90 | 560371 | 1386002 | 126 | 559401 | 1385953 |
| 19 | 560262 | 1388759 | 55 | 560778 | 1387150 | 91 | 560375 | 1385959 | 127 | 559398 | 1385953 |
| 20 | 560322 | 1388731 | 56 | 560779 | 1387118 | 92 | 560377 | 1385927 | 128 | 559218 | 1386005 |
| 21 | 560385 | 1388740 | 57 | 560765 | 1387077 | 93 | 560387 | 1385892 | 129 | 559201 | 1386010 |
| 22 | 560602 | 1388772 | 58 | 560756 | 1387084 | 94 | 560394 | 1385865 | 130 | 559102 | 1386003 |
| 23 | 560797 | 1388731 | 59 | 560724 | 1387034 | 95 | 560397 | 1385855 | 131 | 559046 | 1385998 |
| 24 | 560847 | 1388720 | 60 | 560702 | 1387045 | 96 | 560410 | 1385783 | 132 | 559017 | 1385996 |
| 25 | 561219 | 1388857 | 61 | 560679 | 1387045 | 97 | 560422 | 1385785 | 133 | 559016 | 1385996 |
| 26 | 561295 | 1388883 | 62 | 560649 | 1377054 | 98 | 560568 | 1385694 | 134 | 559014 | 1385996 |
| 27 | 561932 | 1388883 | 63 | 560639 | 1386953 | 99 | 560144 | 1385509 | 135 | 559013 | 1385996 |
| 28 | 561737 | 1387865 | 64 | 560577 | 1386962 | 100 | 560115 | 1385498 | 136 | 558970 | 1385994 |
| 29 | 561702 | 1387852 | 65 | 560550 | 1386885 | 101 | 560110 | 1385497 | 137 | 558969 | 1385994 |
| 30 | 561701 | 1387849 | 66 | 560540 | 1386862 | 102 | 560106 | 1385481 | 138 | 558804 | 1386078 |
| 31 | 561687 | 1387846 | 67 | 560507 | 1386784 | 103 | 559952 | 1385541 | 139 | 558804 | 1386078 |
| 32 | 561475 | 1387807 | 68 | 560437 | 1386675 | 104 | 559910 | 1385557 | 140 | 558499 | 1386167 |
| 33 | 561439 | 1387767 | 69 | 560400 | 1386600 | 105 | 559873 | 1385573 | 141 | 558450 | 1386223 |
| 34 | 561401 | 1387744 | 70 | 560385 | 1386557 | 106 | 559873 | 1385574 | 142 | 560525 | 1385374 |
| 35 | 561363 | 1387720 | 71 | 560378 | 1386533 | 107 | 559859 | 1385578 | 143 | 561932 | 1388989 |
| 36 | 561290 | 1387670 | 72 | 560374 | 1386497 | 108 | 559863 | 1385593 | | | |